# ការស្ថាបនាគេហដ្ឋានដែលផ្ដោតទៅលើព្រះគ្រីស្ទ

អែលឌើរ រីឆាត ជេ ម៉េណេស
នៃកូរ៉ុមពួកចិតសិបនាក់

*យើងយល់ និងជឿទៅលើលក្ខណៈដ៏អស់កល្បនៃគ្រួសារ ។ ការយល់ដឹង និងជំនឿនេះ គួរតែបំផុសឲ្យយើងធ្វើអ្វីគ្រប់យ៉ាងក្នុងអំណាចរបស់យើង ដើម្បីស្ថាបនាគេហដ្ឋានដែលផ្ដោតទៅលើព្រះគ្រីស្ទ*

នៅពេលចាប់ផ្ដើមការបម្រើរបស់ខ្ញុំដំបូង ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាវ័យក្មេង នៅប្រទេសអ៊ុយរុយហ្គាយ និងប៉ារ៉ាហ្គាយ ខ្ញុំបានដឹងអំពីចំណាប់អារម្មណ៍ដ៏អស្ចារ្យមួយរបស់អ្នកទាំងឡាយ ដែលដឹងច្រើនអំពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាចំណាប់អារម្មណ៍របស់ពួកគេទៅលើគោលលទ្ធិអំពីគ្រួសាររបស់យើង ។ តាមពិត ចាប់តាំងពីការស្ដារដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទឡើងវិញ សាសនាគន់ការីដែលស្វែងរកសេចក្ដីពិតត្រូវបាននាំឲ្យខិតមកជិតគោលលទ្ធិ ដែលថាក្រុមគ្រួសារអាចនៅជាមួយគ្នាជារៀងរហូត ។

គោលការណ៍នៃក្រុមគ្រួសារអស់កល្ប គឺជាធាតុមួយដ៏សំខាន់ នៅក្នុងផែនការដ៏មហិមារបស់ព្រះវរបិតាសួគ៌សម្រាប់កូនចៅរបស់ទ្រង់ ។ ចំណុចគ្រឹះនៃផែនការនោះ គឺការយល់ដឹងថា យើងមានគ្រួសារនៅ*សួគ៌ា* ក៏ដូចជាគ្រួសារនៅលើ*ផែនដី* ។ សាវកប៉ុល បង្រៀនយើងថា ព្រះវរបិតាសួគ៌ គឺជាព្រះបិតាខាងវិញ្ញាណរបស់យើង ៖

« ដើម្បីឲ្យគេស្វែងរកព្រះក្រែងគេនឹងរកឃើញទ្រង់ . . .ដោយសារទ្រង់ហើយ ដែលយើងរាល់គ្នាបានរស់ កម្រើក ហើយមាននៅផង . . . ។ ព្រោះយើងក៏ជាពូជព្រះដែរ » ។ [1]

ការជាកូនចៅរបស់ព្រះវរបិតាសួគ៌ជាទីស្រឡាញ់ គឺជាគោលការណ៍គ្រឹះមួយ នៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ សូម្បីតែកុមារតូចៗរបស់យើង ក៏បានប្រកាសអំពីសេចក្ដីពិតនេះផងដែរ នៅពេលពួកគេច្រៀងបទ « ខ្ញុំជាកូនរបស់ព្រះ » តើនៅចាំទំនុកច្រៀងដែរឬទេ ?

*ខ្ញុំជាកូនរបស់ព្រះ*
*ហើយទ្រង់បានចាត់ខ្ញុំមក*
*បានឲ្យផ្ទះខ្ញុំនៅលើផែនដី*
*ជាមួយឪពុកម្ដាយល្អ ។*
*នាំខ្ញុំ ដឹកខ្ញុំ ដើរនៅក្បែរខ្ញុំ*
*ជួយខ្ញុំឲ្យរកផ្លូវ*
*បង្រៀនខ្ញុំអ្វីដែលត្រូវធ្វើ*
*ដើម្បីរស់នៅនឹងទ្រង់ ។* [2]

ការទទួលស្គាល់ថា យើងជាគ្រួសារ *សួគ៌ា* ជួយយើងឲ្យយល់ពីលក្ខណៈដ៏អស់កល្បនៃគ្រួសារនៅលើ*ផែនដី* របស់យើង ។ គោលលទ្ធិ និងសេចក្ដីសញ្ញា បង្រៀនយើងថា គ្រួសារគឺជាគ្រឹះនៃស្ថានសួគ៌ា ៖ « ហើយទំនាក់ទំនងដែលមាននៅក្នុងចំណោមពួកយើងនៅទីនេះយ៉ាងណា នោះក៏នឹងមាននៅក្នុងចំណោមយើងនៅទីនោះយ៉ាងនោះដែរ គ្រាន់តែរួបរួម ដោយសិរីល្អដ៏នៅអស់កល្បជានិច្ច ... » ។ [3]

ការយល់អំពីលក្ខណៈអស់កល្បជានិច្ចនៃគ្រួសារ គឺជាធាតុដ៏សំខាន់ នៅក្នុងការយល់ដឹងអំពីផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់កូនចៅទាំងឡាយរបស់ទ្រង់ ។ ផ្ទុយទៅវិញ មារសត្រូវចង់ធ្វើអ្វីគ្រប់យ៉ាង នៅក្នុងអំណាចរបស់វា ដើម្បីបំផ្លាញផែនការរបស់ព្រះវរបិតា សួគ៌ ។ នៅក្នុងការប៉ុនប៉ងរបស់វា ដើម្បីបំផ្លាញផែនការរបស់ព្រះ វាកំពុងតែដឹកនាំ ការវាយប្រហារថ្មីទៅលើស្ថាប័នគ្រួសារ ។ អាវុធដ៏មានអានុភាពមួយចំនួន ដែលវាប្រើក្នុងការវាយប្រហារ គឺភាពអាត្មានិយម ចិត្តកំណាញ់ និងរូបអាសគ្រាម ។

សុភមង្គលដ៏អស់កល្បរបស់យើង គឺ *ពុំមែន* ជាគោលបំណងរបស់សាតាំងទេ ។ វាដឹងថា គន្លឹះដ៏សំខាន់ដើម្បីធ្វើឲ្យបុរសស្រ្តីវេទនាដូចជាវា គឺការដកយកទំនាក់ទំនងគ្រួសារដែលមានសក្តានុពល*ដ៏អស់កល្ប*ចេញពីពួកគេ ។ ដោយព្រោះសាតាំងយល់ថា សុភមង្គលពិត នៅក្នុងជីវិតនេះ និងភាពអស់កល្បជានិច្ច គឺសង់នៅលើទម្រង់គ្រួសារ វាធ្វើអ្វីគ្រប់យ៉ាងក្នុងអំណាចវាដើម្បីបំផ្លាញ ។

ព្យាការីពីបុរាណឈ្មោះ អាលម៉ា ហៅផែនការរបស់ព្រះ សម្រាប់កូនចៅរបស់ទ្រង់ថា « ផែនការនៃសុភមង្គលដ៏មហិមា » ។ [4] គណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដែលយើងគាំទ្រជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ បានផ្តល់នូវដំបូន្មានដ៏បំផុសគំនិតនេះ ពីសុភមង្គល និងជីវិតគ្រួសារថា ៖

គ្រួសារគឺបានតែងតាំងឡើងដោយព្រះ ។ អាពាហ៍ពិពាហ៍រវាងបុរស និងស្រ្តី គឺសំខាន់ណាស់ ចំពោះផែនការដ៏អស់កល្បជានិច្ចរបស់ទ្រង់ ។ កូនចៅមានសិទ្ធិ ទទួលកំណើតមកក្នុងចំណងអាពាហ៍ពិពាហ៍ ហើយនឹងចិញ្ចឹមបីបាច់ដោយឪពុកម្តាយ ដែលគោរពប្រតិបត្តិតាមសច្ចានៃអាពាហ៍ពិពាហ៍ ដោយស្មោះត្រង់ទាំងស្រុង ។ សុភមង្គលនៅក្នុង ជីវិតគ្រួសារ អាចសម្រេចបានបំផុត នៅពេលធ្វើតាមការបង្រៀននៃព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ » ។ [5]

សុភមង្គលដែលបាននិយាយដោយអាលម៉ានេះ និងដោយគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ថ្មីៗនេះ នឹងសង់ឡើងយ៉ាងពិតនៅក្នុងគេហដ្ឋានជាមួយគ្រួសារ ។ សុភមង្គលនឹងសង់ឡើងយ៉ាងបរិបូរ បើសិនជាយើងធ្វើអ្វីគ្រប់យ៉ាងក្នុងអំណាចយើង ដើម្បីស្ថាបនាគេហដ្ឋានដែលផ្តោតទៅលើព្រះគ្រីស្ទ ។

ស៊ិស្ទើរ ម៉េណេស និងខ្ញុំបានរៀនគោលការណ៍សំខាន់ៗមួយចំនួន នៅពេលយើងចាប់ផ្តើមការស្ថាបនាគេហដ្ឋានដែលផ្តោតទៅលើព្រះគ្រីស្ទ ពេលយើងរៀបការពីដំបូង ។ ចាប់ផ្តើម ដោយការធ្វើតាមដំបូន្មានរបស់អ្នកដឹកនាំសាសនាចក្ររបស់យើង ។ យើងបាននាំកូនៗរបស់យើងមកជួបជុំគ្នា ហើយមានរាត្រីជួបជុំក្រុមគ្រួសារប្រចាំសប្តាហ៍ ក៏ដូចជាការអធិស្ឋាន និងការសិក្សាព្រះគម្ពីររៀងរាល់ថ្ងៃ ។ វាមិនងាយស្រួល ឬមានជោគជ័យជានិច្ចនោះទេ ប៉ុន្តែយូរៗទៅ ការជួបជុំដ៏សាមញ្ញទាំងនេះ ក្លាយទៅជាទំនៀមទម្លាប់ដែលគ្រួសារបានរក្សាទុកមក ។

យើងដឹងថា កូនៗរបស់យើង ប្រហែលជាមិនចាំអ្វីទាំងអស់អំពីមេរៀននៅក្នុងរាត្រីជួបជុំក្រុមគ្រួសារក្នុងសប្តាហ៍ក្រោយមកទេ ប៉ុន្តែពួកគេនឹងចាំថា *យើងបានធ្វើរាត្រីជួបជុំក្រុមគ្រួសារ* ។ យើងដឹងថា ពេលក្រោយមក នៅសាលារៀន ពួកគេនឹងមិនចាំខគម្ពីរ ឬការអធិស្ឋានជាក់លាក់ទេ ប៉ុន្តែពួកគេនឹងចាំថា យើង*បានអាន* គម្ពីរ ហើយយើង *បាន*អធិស្ឋាន ។ បងប្អូនប្រុសស្រី មានអំណាច និងការការពារដ៏មហិមាដល់យើង និងយុវវ័យរបស់យើង ក្នុងការស្ថាបនាទំនៀមទម្លាប់សេឡេស្ទាលក្នុងគេហដ្ឋាន ។

ការរៀន ការបង្រៀន និងការអនុវត្តគោលការណ៍ អំពីដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទនៅក្នុងគេហដ្ឋានរបស់យើង ជួយបង្កើតកន្លែងមួយដែលព្រះវិញ្ញាណអាចគង់នៅ ។ តាមរយៈការបង្កើតទំនៀមទម្លាប់ សេឡេស្ទាលទាំងនេះក្នុងគេហដ្ឋានរបស់យើង នោះយើងនឹងអាចយកឈ្នះលើទំនៀមទម្លាប់ខុសឆ្គងនៃពិភពលោក ហើយរៀនដាក់សេចក្តីត្រូវការ និងកង្វល់របស់អ្នកដទៃមុនគេ ។

ការទទួលខុសត្រូវក្នុងការស្ថាបនាគេហដ្ឋានដែលផ្តោតទៅលើព្រះគ្រីស្ទ គឺអាស្រ័យទៅលើឪពុកម្តាយ និងកូនៗ ។ ឪពុកម្តាយទទួលខុសត្រូវដើម្បីបង្រៀនកូនៗដោយក្តីស្រឡាញ់ និងសេចក្តីសុចរិត ។ ឪពុកម្តាយនឹងទទួលខុសត្រូវចំពោះព្រះអម្ចាស់ តាមរបៀបដែលពួកគេធ្វើភារកិច្ចដ៏ពិសិដ្ឋរបស់ពួកគេ ។ ឪពុកម្តាយបង្រៀនកូនៗ *ដោយ* ពាក្យសម្តី និង *តាមរយៈ* គំរូ ។ កំណាព្យនេះ ដែលស៊ី.ស៊ី. មិល្លី ឲ្យចំណងជើងថា « The Echo » បង្ហាញអំពីសារៈសំខាន់ និងឥទ្ធិពលដែលឪពុកម្តាយមាននៅពេលពួកគេមានឥទ្ធិពលលើកូនៗ ៖

*ព្រះយេស៊ូវប្រាប់រឿងប្រៀបធៀបមួយថា*
*មានចៀមមួយក្បាលបានដើរវង្វេងផ្លូវ*
*ពុំមែនកូនចៀមទេ ជាមេចៀមដែលវង្វេងផ្លូវ*
*ចេញពីហ្វូង កៅសិបប្រាំបួនក្បាល ។*

*ហេតុអ្វីក៏យើងទៅរកមេចៀមដែលបាត់*

*ដោយក្ដីសង្ឃឹម និងការអធិស្ឋានយ៉ាងខ្លាំងនោះ ?*
*ដោយសារតែគ្រោះថ្នាក់ ពេលចៀមដើរខុសផ្លូវ*
*វានឹងនាំឲ្យកូនចៀមវង្វេង ។*

*កូនចៀមនឹងដើរតាមមេចៀម*
*ពេលណាមេចៀមវង្វេង ។*
*ពេលមេចៀមដើរខុសផ្លូវ*
*មិនយូរប៉ុន្មានកូនចៀមនឹងដើរខុសផ្លូវដូចគ្នា ។*

*ដូច្នេះ យើងសុំអង្វរដល់មេចៀម*
*ដើម្បីប្រយោជន៍របស់កូនចៀម*
*ត្បិតពេលមេចៀមបាត់ទៅ*
*តើកូនចៀមនឹងត្រូវបង់ថ្លៃខ្លាំងប៉ុណ្ណា ។*[6]

លទ្ធផលចំពោះឪពុកម្ដាយដែលដឹកនាំកូនៗដែលវង្វេង បានពន្យល់ដល់យើង ដោយព្រះអម្ចាស់នៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញាថា ៖

« ហើយជាថ្មីទៀត ដរាបណាឪពុកម្ដាយមានកូនចៅនៅក្នុងក្រុងស៊ីយ៉ូន ឬ នៅក្នុងស្តេកណាមួយដែលបានរៀបចំឡើងក្តី ដែលពុំបានបង្រៀនកូនចៅឲ្យយល់នូវគោលលទ្ធិអំពីការប្រែចិត្ត សេចក្ដីជំនឿដល់ព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅ និងអំពីបុណ្យជ្រមុជទឹក ហើយនិងអំពីអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ ដោយសារការដាក់ដៃលើ ...ទេ នោះអំពើបាបនឹងធ្លាក់មកលើក្បាលរបស់ឪពុកម្ដាយវិញ» ។[7]
វាពិបាកដើម្បីនិយាយច្រើនពេកអំពីសារៈសំខាន់ ដែលឪពុកម្ដាយមាន ក្នុងការបង្រៀនកូនៗរបស់ពួកគេអំពីទំនៀមទម្លាប់សេឡេស្ទាល តាមរយៈពាក្យសម្ដី និងគំរូ ។ កូនៗក៏មានតួនាទីដ៏សំខាន់ផងដែរ ក្នុងការស្ថាបនាគេហដ្ឋានដែលផ្ដោតទៅលើព្រះគ្រីស្ទ ។ ខ្ញុំសូមចែកចាយដល់អ្នកអំពីការនិយាយដ៏ខ្លីមួយដែលវិល្ល និយាយថ្មីៗនេះ គាត់ជាចៅប្រុសអាយុប្រាំបីឆ្នាំរបស់ខ្ញុំ ដែលបង្ហាញនូវគោលការណ៍នេះ ៖

« ខ្ញុំចូលចិត្តជិះសេះ និងទៅទាក់ចាប់សេះជាមួយនឹងប៉ារបស់ខ្ញុំ ។ ខ្សែពួរ មានអំបោះផ្សេងគ្នាដែលវេញជាមួយគ្នាដើម្បីឲ្យរឹងមាំ ។ បើខ្សែពួរមានអំបោះតែមួយសរសៃ វាមិនអាចប្រើការកើតទេ ។ ប៉ុន្តែដោយសារមានអំបោះច្រើនវេញជាមួយគ្នា នោះយើងអាចប្រើវាបានច្រើនយ៉ាង ហើយវារឹងមាំ ។

« គ្រួសារគឺដូចជាខ្សែពួរ ។ នៅពេលមនុស្សម្នាក់ធ្វើការខ្លាំង ហើយធ្វើអ្វីត្រឹមត្រូវតែម្នាក់ឯង នោះគ្រួសារមិនរឹងមាំដូចជាពេលមានមនុស្សក្នុងគ្រួសារគ្រប់គ្នាខិតខំជួយគ្នានោះទេ។

« ខ្ញុំដឹងថា នៅពេលខ្ញុំធ្វើត្រូវខ្ញុំកំពុងតែជួយដល់គ្រួសារខ្ញុំ ។ នៅពេលខ្ញុំធ្វើល្អចំពោះប្អូនស្រីខ្ញុំ អ៊ីសាបែល នោះយើងទាំងពីរនាក់រីករាយ ហើយធ្វើឲ្យម៉ាក់ប៉ារីករាយផងដែរ ។ បើម៉ាក់ខ្ញុំត្រូវការធ្វើអ្វីមួយ ខ្ញុំអាចជួយគាត់ ដោយទៅលេងជាមួយប្អូនប្រុសតូចរបស់ខ្ញុំ ចូ ។ ខ្ញុំក៏អាចជួយគ្រួសាររបស់ខ្ញុំផងដែរ ដោយការរៀបចំបន្ទប់ឲ្យស្អាត ហើយជួយនៅពេលណាខ្ញុំអាចជួយ ដោយអាកប្បកិរិយាល្អ ។ ដោយសារខ្ញុំជាកូនច្បងក្នុងគ្រួសារ ខ្ញុំដឹងថាការធ្វើជាគំរូល្អគឺសំខាន់ណាស់ ។ ខ្ញុំអាចព្យាយាមឲ្យអស់ពីលទ្ធភាព ដើម្បីជ្រើសរើសត្រូវ ហើយធ្វើតាមព្រះបញ្ញត្តិ ។

« ខ្ញុំដឹងថា កុមារតូចៗអាចជួយដល់គ្រួសាររបស់ពួកគេ ឲ្យរឹងមាំដូចជាខ្សែពួរដ៏មាំផងដែរ ។ នៅពេលមនុស្សគ្រប់រូបខំអស់ពីលទ្ធភាព និងធ្វើការជាមួយគ្នា នោះគ្រួសារនឹងរីករាយ ហើយរឹងមាំ » ។

នៅពេលឪពុកម្ដាយធ្វើជាអធិបតីលើគ្រួសារដោយក្ដីស្រឡាញ់ និងសេចក្ដីសុចរិត ហើយបង្រៀនកូនៗរបស់ពួកគេអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ *តាម* ពាក្យសម្ដី និងគំរូ ហើយនៅពេលកូនៗគាំទ្រ និងស្រឡាញ់ឪពុកម្ដាយ ដោយការរៀនសូត្រ និងការអនុវត្តន៍គោលការណ៍ ដែលឪពុកម្ដាយពួកគេបង្រៀន នោះលទ្ធផលនឹងចេញមក ជាការស្ថាបនាគេហដ្ឋានដែលផ្ដោតទៅលើព្រះគ្រីស្ទ ។

បងប្អូនប្រុសស្រីទាំងឡាយ  ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ  យើងយល់  និងជឿលើលក្ខណៈដ៏អស់កល្បនៃគ្រួសារ ។ ការយល់ដឹង និងជំនឿនេះ គួរតែបំផុសឲ្យយើងធ្វើអ្វីគ្រប់យ៉ាងក្នុងអំណាចរបស់យើង ដើម្បីស្ថាបនាគេហដ្ឋានដែលផ្ដោតទៅលើព្រះគ្រីស្ទ ។ ខ្ញុំថ្លែងទីបន្ទាល់របស់ខ្ញុំដល់អ្នកថា នៅពេលយើងព្យាយាមធ្វើការណ៍នេះ នោះយើងនឹងអនុវត្តក្ដីស្រឡាញ់ និងការបម្រើកាន់តែពេញលេញ ដែលត្រូវបានបង្ហាញនៅក្នុងឆាកជីវិត  និងក្នុងដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ  ព្រះយេស៊ូវគ្រីស្ទ  របស់យើង  ហើយជាលទ្ធផលគេហដ្ឋានរបស់យើងអាចនឹងមានអារម្មណ៍ដូចជាស្ថានសួគ៌នៅលើផែនដី នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. កិច្ចការ 17:27-28 ។
2. ទំនុកដំកើង 58
3. គ. និង ស. 130:2 សូមមើល Robert D. Hales, « The Eternal Family » *Ensign*, ខែ វិច្ឆិកា ឆ្នាំ 1996 ទំព័រ 64 ។
4. អាលម៉ា 42:8
5. « គ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 102។
6. មីលលើរ ស៊ី.ស៊ី « The Echo » នៅក្នុង Best-Loved Poems of the LDS People ដែលបោះពុម្ពដោយ ចាក លីអន et.al. ( ក្រុងសលត៍ លេក ៖ Deseret Book ឆ្នាំ 1996 ) ទំព័រ 312–13 ។
7. គ. និង ស. 68: 25 ។